អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ៖ ១- រាជរដ្ឋាភិបាលខ្មែរមិនគួរចរចាជាមួយថៃជាទ្វេភាគីក្នុងបញ្ហាប្រាសាទព្រះវិហារតទៅទៀតឡើយ គួរប្តឹងទៅតុលាការក្រុងឡាអេ ។ ២- អំពីពិរុទ្ធជនជាតិរុស្ស៊ីម្នាក់ ។ ៣- ការប្រមាថដល់កម្មកររបស់មន្ត្រីក្រសួងការងារខ្មែរ ។

www.hoksavann,com

ថ្ងៃទី២ កញ្ញា ២០១០



ស្ថានការណ៍ប្រទេសកម្ពុជានិងប្រទេសថៃហាក់ដូចជាបានធូរស្រាល បន្ទាប់ពីប្រទេសថៃនិងប្រទេសកម្ពុជាបានបញ្ជូនឯកអគ្គរាជទូតទៅវិញទៅមក ។ សកម្មភាពនេះកើតឡើងបន្ទាប់ពីលោកថាក់ស៊ីនអតីតនាយករដ្ឋមន្ត្រីថៃបានលាលែងពីតំណែងទីប្រឹក្សាផ្ទាល់របស់នាយករដ្ឋមន្ត្រីខ្មែរ និងពីទីប្រឹក្សាសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលខ្មែរ ។ យើងបានបញ្ជាក់ជាញឹកញាប់រួចមកហើយ ថៃត្រូវជាមួយខ្មែរក្តី ថៃទំនាស់ជាមួយខ្មែរក្តី ជាថៃគ្នាគេតែមួយ មានមហិច្ឆិតាចង់បានទឹកដីខ្មែរដូចគ្នា គេចំបែកគ្នាធ្វើការ ជានយោបាយរបស់គេ តែខ្មែរពុំបានពិចារណាឲ្យបានល្អិតល្អន់ខំលូកដៃចូលទៅក្នុងកិច្ចការផ្ទៃក្នុងរបស់គេ ឥឡូវនេះឃើញហើយ គេពុំចូលដៃជាមួយបរទេស (ខ្មែរ) ដើម្បីសម្លាប់ជាតិគេឡើយ ទោះបីគេមានទំនាស់ជាមួយគ្នាគេក៏ដោយ ។ ភាពធូរស្រាលនេះពុំមែនបានន័យថា បញ្ហាប្រាសាទព្រះវិហារនិងដី៤.៦គមនោះបានធូរស្រាលដែរនោះឡើយ ។

ការចរចាជាទ្វេភាគីអស់រយៈកាលជាង២ឆ្នាំហើយ គ្មានបានផលល្អឡើយ ផ្ទុយទៅវិញភាគីទាំង២បានប៉ះទង្គិចគ្នាដោយអាវុធជាច្រើនលើក ដោយត្រូវរបួសនិងស្លាប់ទាំងសងខាងជាច្រើននាក់ ។ ថៃមានការទទូចទៅរកការចរចាជាទ្វេភាគីឡើងវិញ ដោយសាររាជរដ្ឋាភិបាលខ្មែរបានអំពាវនាវអង្គការសហប្រជាជាតិនិងសមាគមអាស៊ានឲ្យជួយដោះស្រាយបញ្ហាទំនាស់រវាងខ្មែរនិងថៃក្នុងបញ្ហាព្រះវិហារនេះ ។ ហេតុដែលនាំឲ្យថៃខ្លាចច្បាប់អន្តរជាតិជាពហុភាគី ព្រោះថៃពុំអាចយកផែនទីដែលខ្លួនគូជាឯកតោភាគីថាដីនៅក្បែរប្រាសាទទំហំ៤.៦គ.ម.ជាដីរបស់ខ្លួន មកសំអាងតាមផ្លូវច្បាប់បានឡើយ ។ ម្ល៉ោះហើយខំព្យាយាមទាក់ទងខ្មែរឲ្យចរចាជាទ្វេភាគី ក្រែងខ្មែរឆោតល្ងង់ប្រគល់ដី៤.៦គ.ម.ឲ្យទៅគេ ។ បើខ្មែរចរចាជាមួយថៃជាទ្វេភាគីតទៅទៀត គឺគ្មានបានផលអ្វីឡើយ ។ ស្រុះស្រួលគ្នាបានលុះត្រាតែខ្មែរប្រគល់ដីទំហំ៤.៦គ.ម.ដែលថៃទាមទារទៅឲ្យថៃ ឬក៏ថៃឈប់ទាមទារដីទំហំ៤.៦គ.ម.នេះ។បើខ្មែរនិងថៃមិនអាចធ្វើដូចពោលមកនេះបានទេការចរចាជាបន្តទៅទៀតគ្មានបានផលអ្វីឡើយ ។

បើខ្មែរប្រគល់បញ្ហានេះទៅឲ្យអ្នកទី៣ គឺច្បាប់អន្តរជាតិដោះស្រាយ ថៃនឹងត្រូវបរាជ័យ ជាពិសេសតុលាការក្រុងឡាអេដែលកាត់ឲ្យខ្មែរឈ្នះក្តីព្រះវិហារឆ្នាំ១៩៦២ ។ ពេលនោះគេបង្ខំឲ្យថៃដកទ័ពរបស់ខ្លួនចេញពីប្រាសាទព្រះវិហារ ហើយរបស់ទ្រព្យដែលដីប្រមូលយកទៅត្រូវតែប្រគល់ឲ្យខ្មែរវិញ ។ បើតុលាការក្រុងឡាអេសើរើសេចក្តីសំរេចឡើងវិញ កងទ័ពចោរសៀមដែលស្ថិតនៅក្បែរប្រាសាទព្រះវិហារ និងវត្តកែវសិក្ខាគីរីស្វារៈសព្វថ្ងៃនេះ ត្រូវតែចាកចេញទៅប្រទេសថៃវិញ ព្រោះទឹកដីនេះជារបស់ប្រទេសកម្ពុជា ។ បើកាត់ឲ្យខ្មែរឈ្នះព្រះវិហារ ទីដីព្រះវិហារនិងដីក្បែរព្រះវិហារក៏ជារបស់ខ្មែរ ។ តាំងពីនោះរហូតមកទល់ពេលនេះចំនួន៤៨ឆ្នាំហើយ ថៃសុខចិត្តពុំទាមទារអ្វីឡើយ ទើបតែពេលនេះ បែរជាថៃប្រឆាំងនឹងការដាក់ប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក រហូតទាមទារដីទំហំ៤.៦គ.ម. ដែលស្ថិតនៅក្បែរប្រាសាទព្រះវិហារថែមទៀត ។

២- ក្រុមប្រឹក្សាធម្មនុញ្ញគប្បីស៊ើបអង្កេតចៅក្រមបន្ថយទោសមិនប្រក្រតីចំពោះជនជាតិរុស្ស៊ីម្នាក់ ៖

កាលពីថ្ងៃទី២៦សីហា២០១០ សាលាឧទ្ធរណ៍បានបន្ថយទោសជនជាតិរុស្ស៊ីម្នាក់ឈ្មោះ អាឡិចស្ទីនដ័រ-ត្រូស៊ីម៉ិល ឲ្យជាប់គុកពី១៧ឆ្នាំមក៨ឆ្នាំវិញ ដោយមូលហេតុថា ជនជាតិរុស្ស៊ីរូបនេះបានសុំខមាទោសចំពោះស្រីខ្មែរចំនួន១៩នាក់ដែលខ្លួនបានរំលោភ ហើយថាខ្លួនពុំបានដឹងថាអំពើនេះខុសច្បាប់នៅប្រទេសកម្ពុជា ។ ការបន្ថយទោសដោយមូលហេតុនេះ ជាការបន្ថយទោសមិនប្រក្រតី ជាការមើលងាយស្រីខ្មែរដែលវារំលោភ ។ អ្នកណាក៏ដឹងថា ការរំលោភស្រីជាទោសអន្តរជាតិដែលពិភពលោកកំពុងនាំគ្នាកំចាត់ ពុំមែនវាពុំដឹងនោះទេ ។ ទោះបីវាពុំដឹង ក៏មិនត្រូវបន្ថយទោសដែរ ត្រូវតែធ្វើទោសតាមច្បាប់របស់ខ្មែរ ។ យើងសូមសួរទៅចៅក្រមសាលាឧទ្ធរណ៍ខ្មែរនេះថា តើបានទទួលប្រាក់សំណូកពីជនជាតិរុស្ស៊ីនេះឬទេ ? ហើយតុលាការកំពូលដែលពុំព្រមកាត់ទោសវា បែរជាបង្ខិលឲ្យសាលាឧទ្ធរណ៍សើរើឡើងវិញ តើបានទទួលប្រាក់សំណូកប៉ុន្មានលានដុល្លារដែរឬទេ ? ព្រោះមហាសេដ្ឋីជនជាតិរុស្ស៊ីនេះមានលុយច្រើន គ្រាន់តែវាបំរុងធ្វើវិនិយោគទុននៅកោះពស់ខេត្តព្រះសីហនុ មានចំនួន៣០០លានដុល្លារ ។ ដូច្នេះវាអាចចំណាយតែ១០លានដុល្លារទៅចៅក្រមខ្មែរក៏វាពុំស្តាយដែរ ឲ្យតែវាបានរួចខ្លួនពីការជាប់គុក ។ ប៉ុន្តែចៅក្រមឆ្លាតដែរ មិនហ៊ានឲ្យរួចទោសទាំងអស់ទេ ឲ្យនៅជាប់ទោសខ្លះ ព្រោះខ្លាចគេចោទថាពុករលួយ ។ ដើម្បីឲ្យដឹងការពិត ក្រុមប្រឹក្សាធម្មនុញ្ញគប្បីធ្វើការស៊ើបអង្កេតចៅក្រមបន្ថយទោសជនជាតិរុស្ស៊ីនេះ បើឃើញភស្តុតាងត្រូវតែធ្វើទោសតាមកំហុស ។

៣- មន្ត្រីក្រសួងការងារខ្មែរបាននិយាយប្រមាថមើលងាយកម្មករកាត់ដេរខ្មែរ ៖

កម្មករកាត់ដេរខ្មែរបានធ្វើសំណូមពរឲ្យតម្លើងប្រាក់ខែពី៧០ទៅ៩០ដុល្លារ ទើបរស់នៅបានជាបង្គួរ រហូតព្រមានធ្វើកូដកម្ម ។ មន្ត្រីក្រសួងការងារខ្មែរបាននិយាយប្រមាថមើលងាយកម្មករកាត់ដេរខ្មែរថា ការធ្វើកូដកម្មទុកជាការរំលំឆ្នាំងបាយខ្លួនឯង ។ សំដីព្រហើនកោងកាចអសីលធម៌នេះ ជាសំដីពុំទទួលខុសត្រូវមើលងាយប្រជាពលរដ្ឋទន់ខ្សោយ ជាសំដីគំរាមជៀសវាងការដោះស្រាយ ។ ការធ្វើបាតុកម្ម កូដកម្ម ជាសិទ្ធិរបស់ប្រជាពលរដ្ឋដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ។ មួយទៀតការធ្វើច្បាប់ធ្វើបាតុកម្ម កូដកម្ម ដោយកំណត់ទីកន្លែងនិងកំណត់ចំនួនមនុស្ស ជាច្បាប់រំលោភសិទ្ធិមនុស្ស ជាច្បាប់ខុសគេក្នុងពិភពលោក ។ ចំពោះការតម្លើងប្រាក់ខែ៥ដុល្លារលើប្រាក់ខែគោល ហើយថា៨ឆ្នាំទើបនិយាយគ្នាម្តងទៀត ជាការតម្លើងតិចតួច ដែលជានុយមើលងាយពលករខ្មែរដូចខ្ញុំកញ្ជះដាច់ថ្លៃ មិនសមស្របនឹងទំនិញសព្វសារពើឡើងថ្លៃរហូតដល់៨ឆ្នាំទៀត តើក្នុងរយៈកាលនេះសេដ្ឋកិច្ចឡើងចុះដល់ថ្នាក់ណាទៀត នៅពេលដែលប្រាក់ខែនៅដដែល នេះជាការសំរេចគ្មានសមធម៌ ។ ក្រុមហ៊ុនទាំងនោះបានចំណេញច្រើនណាស់ គួរតែតម្លើងតាមពាក្យសុំ ។ ការពុំព្រមតម្លើងនេះ ពុំមែនកំហុសនៅលើក្រុមហ៊ុនទេ គឺនៅលើមន្ត្រីរាជរដ្ឋាភិបាលខ្មែរវិញទេ ។ ការតម្លើងតាមពាក្យសុំនេះ ពុំអាចឲ្យក្រុមហ៊ុនទាំងនេះទៅរកស៊ីនៅប្រទេសផ្សេងទៀតទេ ផ្ទុយទៅវិញពួកនេះអាចចេញពីប្រទេសខ្មែរ មានមូលហេតុតែម៉្យាង គឺអំពើពុករលួយរបស់មន្ត្រីខ្មែរបង្ខំយកប្រាក់ក្រោមតុប្រាក់ទឹកតែច្រើនពេកវិញទេ ។៚

*                    *

*